**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

# សេចក្តីប្រកាសព័ត៌មាន

**ក្រសួងមុខងារសាធារណៈ** សូមជម្រាបជូនដំណឹងជាសាធារណៈថា កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ក្រសួងមុខងារសាធារណៈ បានទទួលពាក្យបណ្ដឹងរបស់លោក ខឹម មុនីកុសល មន្ត្រីមន្ទីរសុខាភិបាលខេត្តប៉ៃលិន ដែលបានប្ដឹងជំទាស់ដីកាលេខ ០១៨/២១ ដក.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តប៉ៃលិន ចំពោះការសម្រេចលុបឈ្មោះសាមីខ្លួនចេញពីក្របខ័ណ្ឌរដ្ឋ។

ដោយអនុវត្តតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមុខងារសាធារណៈ តាមលិខិតរបស់ខ្លួនលេខ ៩៤៦ មស.នក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ បានបង្វែរពាក្យបណ្ដឹងនេះទៅឱ្យរដ្ឋបាលខេត្តប៉ៃលិន បង្កើតគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ដើម្បីពិនិត្យដោះស្រាយឡើងវិញឱ្យស្របតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន ។

ជាលទ្ធផល គណៈកម្មាធិការនេះបានតម្កល់ដីការបស់រដ្ឋបាលខេត្តប៉ៃលិនស្ដីពីការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ បណ្ដេញលោក ខឹម មុនីកុសល ចេញពីក្របខ័ណ្ឌរដ្ឋឱ្យនៅដដែល តាមលិខិតរបស់រដ្ឋបាលខេត្តប៉ៃលិន លេខ១៩៣/២១ របក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ផ្ញើមកក្រសួងមុខងារសាធារណៈ។

លោក ខឹម មុនីកុសល បានដាក់ពាក្យបណ្ដឹងជាលើកទី២ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ ជំទាស់នឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈខេត្តប៉ៃលិន។

កិច្ចប្រជុំរវាងតំណាងក្រសួងមុខងារសាធារណៈ និងតំណាងក្រសួងមហាផ្ទៃ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១ បានជួយពិនិត្យបន្ថែមទៀតពីនីត្យានុកូលភាពនៃដីកាលេខ ០១៨/២១ ដក.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តប៉ៃលិន ឃើញថាស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អនុលោមតាមអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្ដីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្ម និងអធិការកិច្ច ក្រសួងមុខងារសាធារណៈបានបង្កើតក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពមកពីក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ដើម្បីចុះទៅពិនិត្យស្រាវជ្រាវករណីនេះនៅខេត្តប៉ៃលិន កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២។

ក្រោយការចុះទៅពិនិត្យស្រាវជ្រាវជាក់ស្ដែង ល្អិតល្អន់ដល់ទីកន្លែង និងការជួបប្រជុំជាមួយអង្គភាព និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងសាមីជនជាដើមបណ្ដឹងផង ក្រុមការងារអន្តរក្រសួងបានផ្ដល់លទ្ធផលស្រាវជ្រាវលម្អិតសន្និដ្ឋានសម្រាប់ការសម្រេចចុងក្រោយលើករណីបណ្ដឹងតវ៉ារបស់លោក ខឹម មុនីកុសល។

ក្រោយពីបានពិនិត្យលើដំណើរការនៃការស្រាវជ្រាវ និងផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ពីនីតិវិធីអធិការកិច្ចដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដូចបានរៀបរាប់ខាងលើ **ក្រសួងមុខងារសាធារណៈ សម្រេចថា** ការចេញដីកាលេខ ០១៨/២១ ដក.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តប៉ៃលិន ស្ដីពីការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ចំពោះលោក ខឹម មុនីកុសល គឺស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន៕

ថ្ងៃ សុក្រ ៣កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០២២